ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*ថ្ងៃ ចន្ទ ១០ រោច ខែ ជេស្ឋ ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការប្រកាសដាក់ដំណើរការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

នាព្រឹកថ្ងៃ ច័ន្ទ ទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ នេះ, នាវេលាម៉ោង ១០ ព្រឹក នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើជាអធិបតីក្នុង **"ពិធីប្រកាសដាក់ដំណើរការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន"** ដោយមានការចូលរួមពីសំណាក់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សមាគមតំណាងវិស័យឯកជន និងក្រុមអ្នកសារព័ត៌មាន ។

**"ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន"** ជាបង្គោលចរថ្មីមួយនៃការកែទម្រង់មុតស្រួចរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងលើកកម្ពស់ភាពប្រកួតប្រជែង និងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគនៅព្រះរាជាណា-ចក្រកម្ពុជា ។

ចាប់ពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ នេះតទៅ, ធុរជនអាចធ្វើការចុះបញ្ជីអាជីវកម្មថ្មីបាន តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន **<u>ជាកញ្ចប់</u>** ដែលមានអាសយដ្ឋាន www.registrationservices.gov.kh ដូចជាការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម, ការចុះបញ្ជីពន្ធដារ នៅអគ្គនាយកដ្ឋានពន្ធដារ និងការធ្វើសេចក្តីប្រកាសផ្តល់ដំណឹងបើកសហគ្រាស ជូនទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **ក្នុងពេលតែមួយ និង ត្រូវការពេលវេលាយ៉ាងយូរត្រឹម ៨ ថ្ងៃ នៃថ្ងៃធ្វើការប៉ុណ្ណោះ ជាមួយនឹងការចំណាយតិចជាងមុនរហូតជាងពាក់កណ្តាល** ។ ទន្ទឹមនឹងនេះ, វិនិយោគិនអាចស្នើសុំចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់(QIP)តាមថ្នាលបច្ចេកវិទ្យាព័ត៌មាននេះផងដែរ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

ប្រព័ន្ធចុះបញ្ជីអាជីវកម្ម និងយន្តការថ្មីនេះ គឺជាប្រព័ន្ធទីមួយរបស់រាជរដ្ឋាភិបាល ដែលមានការតភ្ជាប់ផ្លាស់ប្តូរទិន្នន័យ ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងក្របខណ្ឌ ជាប្រព័ន្ធអេកូឡូហ្ស៊ី ហើយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាលក្ខណៈអន្តរក្រសួង ដោយទិន្នន័យទាំងអស់

នឹងត្រូវបានបញ្ជូនចែករំលែកដោយស្វ័យប្រវត្តិ ទៅប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការត្រួតពិនិត្យ និង ផ្តល់កាអនុម័ត ។ ដំណើការនៅក្នុងការចុះបញ្ជី, ការដាក់ឯកសារយោង ក៏ដូចជាការទទួលបានមកវិញ នូវវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម, វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ, បណ្ណប៉ាតង់ ក៏ដូចជាឯកសារផ្សេងទៀតទាំងអស់ នឹងត្រូវផ្តល់ និងទទួលបានជាទម្រង់ឌីជីថល ដែលនឹងត្រូវបានធ្វើឡើងទាំងស្រុងនៅលើថ្នាលបច្ចេកវិទ្យាព័ត៌មាន ហើយមិនមានការប្រើប្រាស់ជាឯកសាររូបី ក្នុងទម្រង់រឹងទៀតទេ ។ តាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាននេះ, នីតិវិធីស្មុគស្មាញ, ការផ្តល់ព័ត៌មានច្រើនដង និងច្រំដែល, ពេលវេលា និង ការចំណាយ ដែលកើតមាននៅតាមបណ្តាដំណាក់កាលនៃការចុះបញ្ជីអាជីវកម្ម នៅក្នុងក្របខណ្ឌយន្តការចាស់ ត្រូវបានកាត់បន្ថយជាអតិបរមា ។

លើសពីនេះ, ប្រព័ន្ធចុះបញ្ជីអាជីវកម្មថ្មីនេះ នឹងផ្តល់ឱកាសដ៏សំខាន់មួយទៀតផងដែរ ដល់ធុរ-ជនដែលកំពុងស្វែងរកឯកសារគតិយុត្តកំណត់អត្តសញ្ញាណអាជីវកម្មរបស់ខ្លួន ដើម្បីពន្លឿន និងទទួលបានឥណទានពីកម្មវិធីហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាល ក្នុងវិធានការជួយដល់វិស័យឯកជន ដែលទទួលរងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ ។

ពិធីប្រកាសដាក់ដំណើរការជាផ្លូវការនូវ **"ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន"** នាពេលនេះគ្រាន់តែជាដំណាក់កាលទី ១ ដែលផ្តោតជាសំខាន់លើការចុះបញ្ជីអាជីវកម្មថ្មីតែប៉ុណ្ណោះ ។ នៅក្នុងដំណាក់កាលបន្ទាប់, រាជរដ្ឋាភិបាលនឹងបន្តពង្រីកវិសាលភាពនៃប្រព័ន្ធនេះ ឈានទៅគ្របដណ្តប់ដល់គ្រប់ក្រសួង-ស្ថាប័នផ្សេងទៀត ដើម្បីរៀបចំការផ្តល់អាជ្ញាបណ្ណនានាតាមថ្នាលបច្ចេកវិទ្យាព័ត៌មានថែមទៀត ។

លទ្ធផលនៃការកសាងប្រព័ន្ធនេះ បានបង្ហាញយ៉ាងច្បាស់ថា ទោះបីជាកម្ពុជា, ក៏ដូចជាពិភព-លោកទាំងមូល, កំពុងតែបន្តទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩, រាជរដ្ឋាភិបាល, ក្រោមការដឹកនាំប្រកបដោយបញ្ញាញាណដ៏ឈ្លាសវៃ, ចក្ខុវិស័យវែងឆ្ងាយ និង ភាពប្រាកនិយមរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, មិនបានបន្ថយល្បឿននៃការងារកែទម្រង់របស់ខ្លួនទេ ។ ផ្ទុយទៅវិញ, រាជរដ្ឋាភិបាលបានចាត់ទុកកាលៈទេសៈនៃវិបត្តិនេះ គឺជាកាលានុវត្តភាពសម្រាប់ជំរុញកិច្ចការកែទម្រង់មុតស្រួច ឱ្យកាន់តែសកម្មឡើងថែមទៀត ដើម្បីឆ្លើយតបទៅនឹងវិបត្តិផង និង សំលៀងសម្រួចភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ សំដៅជំរុញធ្វើពិពិធកម្មមូលដ្ឋាននៃកំណើន និង គាំទ្រដល់កំណើនប្រកបដោយចីរភាពសម្រាប់រយៈពេលវែងផង ។